ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

CAMBODIA
Kingdom of Wonder
ទីក្រុងស្អាត ត្រូវផ្ដើមចេញពីយើងទាំងអស់គ្នា

គណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត
លេខ:០០១.សាសរ.គជវទ

រាជធានីភ្នំពេញ ថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៤

# សេចក្ដីសម្រេច

## បង្កើតក្រុមការងារបច្ចេកទេសវាយតម្លៃលើការប្រឡងប្រណាំង "រង្វាន់សម្ដេចតេជោនាយករដ្ឋមន្ត្រីសម្រាប់ធុរកិច្ចបៃតងក្នុងវិស័យទេសចរណ៍"

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១២ ស្ដីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០២/នស/រកម/០១៩៦/១៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៩/០០៧ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីទេសចរណ៍
- យោងតាមសំណូមពរចាំបាច់របស់ក្រសួងទេសចរណ៍

### សម្រេច

**ប្រការ ១.**_ ត្រូវបានបង្កើតក្រុមការងារបច្ចេកទេសដើម្បីវាយតម្លៃលើការប្រឡងប្រណាំងរង្វាន់សម្ដេចតេជោនាយករដ្ឋមន្ត្រីសម្រាប់ធុរកិច្ចបៃតងក្នុងវិស័យទេសចរណ៍មានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១.ឯកឧត្ដម **ឈោម សាមុត** | អគ្គនាយកទេសចរណ៍ | ប្រធាន |
| ២. ឯកឧត្ដម **អាំង សុវណ្ណរ័ត្ន** | អគ្គនាយករងទេសចរណ៍ | អនុប្រធានអចិន្ត្រៃយ៍ |
| ៣. ឯកឧត្ដម **ជួន ជ័យសត្យា** | អគ្គលេខាធិការរង គ.ជ.វ.ទ. | អនុប្រធាន |
| ៤. ឯកឧត្ដម **ឈុន មករា** | អគ្គលេខាធិការរង គ.ជ.វ.ទ. | សមាជិក |
| ៥. លោក **ទ្រី ឈឿន** | អគ្គនាយករងទេសចរណ៍ | សមាជិក |
| ៦. លោក **ឆាយ ឃុនឡុង** | អគ្គនាយករងទេសចរណ៍ | សមាជិក |

| | | |
|---|---|---|
| ៧. លោក **គីម សេរីរដ្ឋ** | ប្រធាននាយកដ្ឋានឧស្សាហកម្មទេសចរណ៍ | សមាជិក |
| ៨. លោក **ជុត ជំនោរ** | ប្រធាននាយកដ្ឋានទេសចរណ៍វប្បធម៌ និងរមណីយដ្ឋាន | សមាជិក |
| ៩. លោក **ម៉ិត វិទ្ធី** | ប្រធានផ្នែកសហប្រតិបត្តិការ និងផ្សព្វផ្សាយ គ.ជ.វ.ទ. | សមាជិក |
| ១០. លោក **ប្រឡឹង សុមេធា** | ប្រធានផ្នែកផែនការ បណ្តុះបណ្តាល និងនីតិកម្ម គ.ជ.វ.ទ. | សមាជិក |
| ១១. លោក **លន់ ប៊ុនធឿន** | ប្រធានផ្នែករដ្ឋបាល និងហិរញ្ញវត្ថុ គ.ជ.វ.ទ. | សមាជិក |
| ១២. លោក **នាង ចំណាប់** | អនុប្រធានផ្នែកសហប្រតិបត្តិការ និងផ្សព្វផ្សាយ គ.ជ.វ.ទ. | លេខាធិការ |
| ១៣. លោក **គុណ គឹមជួរ** | អនុប្រធានផ្នែករដ្ឋបាល និងហិរញ្ញវត្ថុ គ.ជ.វ.ទ. | សមាជិក |

ក្រុមការងារបច្ចេកទេសនេះ មានភារកិច្ច និងតួនាទីដូចខាងក្រោមៈ

- វាយតម្លៃលើការប្រឡងប្រណាំងរង្វាន់សម្តេចតេជោនាយករដ្ឋមន្ត្រីសម្រាប់ធុរកិច្ចបៃតងក្នុងវិស័យទេសចរណ៍ឱ្យទទួលបានជោគជ័យ និងប្រសិទ្ធភាព
- សហការជាមួយមន្ទីរទេសចរណ៍រាជធានី-ខេត្តក្នុងការវាយតម្លៃលើចលនាប្រឡងប្រណាំងរង្វាន់សម្តេចតេជោនាយករដ្ឋមន្ត្រីសម្រាប់ធុរកិច្ចបៃតងក្នុងវិស័យទេសចរណ៍
- រៀបចំបណ្តុះបណ្តាលអ្នកវាយតម្លៃ (Master Assessor) រង្វាន់សម្តេចតេជោនាយករដ្ឋមន្ត្រីសម្រាប់ធុរកិច្ចបៃតងក្នុងវិស័យទេសចរណ៍
- ធ្វើការទទួល និងប្រមូលទិន្នន័យរបស់ធុរកិច្ចបេក្ខភាពដែលបានដាក់ពាក្យស្នើសុំក្នុងចលនាប្រឡងប្រណាំងរង្វាន់សម្តេចតេជោនាយករដ្ឋមន្ត្រីសម្រាប់ធុរកិច្ចបៃតងក្នុងវិសយទេសចរណ៍
- ធ្វើការពិនិត្យ និងវាយតម្លៃ (Short List) លើពាក្យសុំ និងឯកសារយោងរបស់ធុរកិច្ចបេក្ខភាព
- ធ្វើការវាយតម្លៃលើកចុងក្រោយជូន **ឯកឧត្តមរដ្ឋមន្ត្រីក្រសួងទេសចរណ៍** ពិនិត្យ និងសម្រេច ។

**ប្រការ ២.**_ ក្រុមការងារនេះមានសិទ្ធិជ្រើសរើសបន្ថែមសមាសភាពតាមការចាំបាច់របស់ការងារ។

**ប្រការ ៣.**_ ក្រុមការងារនេះមានសិទ្ធិប្រើប្រាស់ត្រា និងថវិការរបស់ក្រសួងទេសចរណ៍ក្នុងករណីចាំបាច់ ។

**ប្រការ ៤.**_ សាមីខ្លួនដូចមានចែងក្នុងប្រការ ២ ត្រូវចូលរួមអនុវត្តន៍សេចក្តីសម្រេចនេះ ឱ្យមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**គណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត**

**ប្រធាន**

**ថោង ខុន**

**រដ្ឋមន្ត្រីក្រសួងទេសចរណ៍**

**ចម្លងជូនៈ**

- ខុទ្ទកាល័យឯកឧត្តមរដ្ឋមន្ត្រី
- ឯកឧត្តមអគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ
- មន្ទីរទេសចរណ៍រាជធានី-ខេត្ត

"សហការ"

- ឯកសារ-កាលប្បវត្តិ